**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គលេខាធិការដ្ឋាន**

**នាយកដ្ឋានបុគ្គលិក**

ថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ ÷** របាយការណ៍ស្តីពីបច្ចុប្បន្នភាពកម្រិតសញ្ញាបត្រ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីរបស់មន្ត្រីរាជការក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២២។

**យោង ÷** ប្រកាសលេខ ៧៨១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកំណត់វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា យោងប្រកាសលេខ ៧៨១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកំណត់វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ការិយាល័យជំនាញបានបូកសរុប និងធ្វើការវិភាគលើរបាយការណ៍ស្ថិតិរបស់អង្គភាពក្រោមឱវាទក្រសួង ដោយទទួលបានលទ្ធផលដូចខាងក្រោម÷

១.កម្រិតសញ្ញាបត្រមន្ត្រីក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ២០២២ មានចំនួន ៦៥៣៥ នាក់ ស្ត្រីចំនួន ២០០៤ នាក់ ដោយក្នុងនោះមាន ÷

(ក). សញ្ញាបត្រថ្នាក់បណ្ឌិត មានចំនួន ៨២ នាក់ ស្មើ ១.២៥%

(ខ). សញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ២៤៦៦ នាក់ ស្មើ ៣៧.៧៤%

(គ). សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ មានចំនួន ៣២៨៩ នាក់ ស្មើ ៥០.៣៣%

(ឃ). សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង មានចំនួន ២៧៦ នាក់ ស្មើ ៤.២២%

(ង). សញ្ញាបត្រថ្នាក់បឋម/ទុតិយភូមិ មានចំនួន ៤២២ នាក់ ស្មើ ៦.៤៦%។

២. ស្ថានភាពប្រែប្រួលការចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីទាំងក្នុង និងក្រៅប្រទេសមានចំនួន ៤២០៥នាក់ ស្ត្រីចំនួន ១២៥៥នាក់ ដែលភាគច្រើនសិក្សាតាមប្រព័ន្ធអនឡាញ ក្នុងនោះមានតួនាទី ចាប់ពីអគ្គនាយករងដល់អគ្គនាយក មានចំនួន ២៥នាក់ អនុប្រធានអង្គភាពដល់ប្រធានអង្គភាព មានចំនួន ៤៩០នាក់ អនុប្រធានការិយាល័យដល់ប្រធានការិយាល័យ មានចំនួន ១៥៣២នាក់ និងមន្ត្រី មានចំនួន ២១៥៨នាក់ ដោយផ្តោតសំខាន់លើមុខវិជ្ជាសិក្សាចម្រុះៗដូចតទៅ ÷

(ក). ថវិកាកម្មវិធី

(ខ). ព័ត៌មានវិទ្យា

(គ). កិច្ចលទ្ធកម្ម

(ឃ). ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

(ង). ការប្រើប្រាស់ការគ្រប់គ្រងហិរញ្ញវត្ថុតាមព័ត៌មានវិទ្យា FMIS ព្រមទាំងមុខវិជ្ជាផ្សេងៗទៀត ដូចមានឯកសារវិភាគលម្អិតជូនភ្ជាប់មកជាមួយ។

៣. ក្នុងន័យធានាបាននូវបច្ចុប្បន្នភាពទិន្នន័យត្រឹមត្រូវស្របតាមបម្រែបម្រួលជាក់ស្តែង ការិយាល័យជំនាញសូមស្នើសុំដាក់បញ្ចូលទិន្នន័យដែលបានមកពីរបាយការណ៍ខាងលើទៅក្នុងគេហទំព័ររបស់នាយកដ្ឋានបុគ្គលិកជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមអនុវត្តពីឆ្នាំ២០២៣ នេះតទៅ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តានិត្យសម្រេច និង/ឬ ផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ប្រធានការិយាល័យ**

**គ្រប់គ្រងការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្ស**

**ទុយ សុខហេង**

[illegible]

9/11/23